**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ២ រោច ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងាររវាង
## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម ម៉ាសាស៊ូហ្គូ អាសាកាវ៉ា
## (Masatsugu Asakawa) ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

នាព្រឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២២ នេះ, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** (Masatsugu Asakawa) **ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូល Indonesia Malaysia Thailand - Growth Triangle (IMT-GT) ក្នុងអំឡុងនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០ និង ៤១ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ៨ ដល់ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** និងសហការី ក្នុងឱកាសបំពេញការងារនៅប្រទេសកម្ពុជា និងវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែកដ៏សំខាន់របស់ ADB ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងការគាំទ្រកម្ពុជាក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩២ មក ទាំងផ្នែកហិរញ្ញវត្ថុ, ផ្នែកបច្ចេកទេស ។ ជាពិសេស, ADB បានដើរតួនាទីយ៉ាងសំខាន់ជួយរាជរដ្ឋាភិបាលឆ្លើយតបភ្លាមៗក្នុងកាលៈទេសៈដ៏លំបាក ដែលក្នុងនោះ ការផ្តល់ហិរញ្ញប្បទានភ្លាមៗ ចំនួន ២៥០ លានដុល្លារអាមេរិក ជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងការផ្តល់ហិរញ្ញប្បទានបន្ថែមភ្លាមៗ ចំនួន ៤០០ លានដុល្លារអាមេរិកទៀត សម្រាប់ការបន្តគាំទ្ររាជរដ្ឋាភិបាលក្នុងការស្តារឡើងវិញនូវសេដ្ឋកិច្ច ក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការអនុវត្ត **“ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣”** ។

ឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** បានថ្លែងកោតសរសើរ និងអបអរសាទរ ចំពោះភាពជោគជ័យលើសមរភូមិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេលលើសជាង ២ឆ្នាំ កន្លងទៅនេះ ជាពិសេស ការដាក់ចេញនូវ **“ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ សំដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១”** កម្ពុជាបានសម្រេចការចាក់វ៉ាក់សាំងជូនប្រជាជនប្រមាណ ៩១,១២% (បានចាក់គ្រប់ដូស) ធៀបនឹងប្រជាជនសរុបចំនួន ១៦ លាននាក់ ។ ជាមួយគ្នានេះដែរ, ឯកឧត្តម **ម៉ាសាស៊ូហ្គូ អាសាកាវ៉ា** បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានកសាង និងពង្រឹងកិច្ចសហប្រតិបត្តិការដ៏ល្អ និងរឹងមាំជាមួយ ADB ក្នុងរយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ ហើយឯកឧត្តមបានត្រៀមខ្លួនជាស្រេច ដើម្បីឱ្យកិច្ចសហប្រតិបត្តិការដ៏ល្អនេះ កាន់តែត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀតសម្រាប់រយៈពេលខាងមុខ សំដៅបន្តរួមចំណែកដោះស្រាយបញ្ហាប្រឈមនានាក្នុងកិច្ចដំណើរការអភិវឌ្ឍន៍របស់កម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់សុភវិនិច្ឆ័យរបស់ឯកឧត្តម **ម៉ាសា ស៊ូហ្គូ អាសាកាវ៉ា** និងបានមានប្រសាសន៍ថា ជោគជ័យរបស់កម្ពុជាក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ និងភាពរឹងមាំនៃការស្តារសម្បទាសេដ្ឋកិច្ចឡើងវិញ គឺកើតចេញពីសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ ឆ្លាតវៃ និងម៉ឺងម៉ាត់របស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា សម្រាប់កម្ពុជា, ការរក្សាសុខសន្តិភាព និងស្ថិរភាពនយោបាយ ជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍប្រទេស ។ បើទោះបីជា កម្ពុជាបានទទួលជោគជ័យលើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយការសម្រេចបាននូវភាពស៊ាំនៃសហគមន៍តាមរយៈយុទ្ធសាស្ត្រនៃការចាក់វ៉ាក់សាំង ព្រមទាំងបានបើកប្រទេស និងសេដ្ឋកិច្ចឡើងវិញក៏ពិតមែន ប៉ុន្តែនៅចំពោះមុខកម្ពុជាមើលឃើញអំពីបញ្ហាប្រឈមមួយចំនួនដែលមានដូចជា បញ្ហាវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងជម្លោះភូមិសាស្ត្រនយោបាយដែលបាននិងកំពុងកើតមានឡើង ហើយបានបង្កជាកង្វល់ និងវិបត្តិសេដ្ឋកិច្ចជាសាកល ដោយបានផ្តល់ផលប៉ះពាល់ទាំងដោយផ្ទាល់ និងដោយប្រយោលនៅទូទាំងពិភពលោក រួមទាំងកម្ពុជា ផងដែរ ។ ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងខិតខំរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាពរបស់ខ្លួន ដើម្បីគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ជាពិសេស កាត់បន្ថយការរងសម្ពាធនៃអតិផរណារជាសាកល ជាមួយនឹងការគាំទ្រការស្តារសម្បទានិងការហក់ឡើងនៃកំណើនសេដ្ឋកិច្ច ។

ជាមួយគ្នានេះ, ADB បានសន្យាផ្តល់ហិរញ្ញប្បទានក្នុងទំហំទឹកប្រាក់ ១០០ ពាន់លានដុល្លារអាមេរិក ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់សម្រាប់ឆ្នាំ ២០១៩-២០៣០ ដែលក្នុងនោះមានកម្ពុជាផងដែរ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្វាគមន៍ និងគាំទ្រទាំងស្រុងចំពោះការលើកឡើងនូវគោលនយោបាយគន្លឹះទាំង ៤ របស់ ADB÷ ១. បង្កើនការផ្តល់ហិរញ្ញប្បទាន, ២. ជំរុញការចូលរួមរបស់វិស័យឯកជនដោយប្រើប្រាស់យន្តការហិរញ្ញប្បទានប្រកបដោយនវានុវត្តន៍, ៣. កសាងសមត្ថភាព និងចំណេះដឹង, និង ៤. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ស្តីពីការឆ្លើយតប និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។ តែទោះជាយ៉ាងណា, ការលើកកម្ពស់ការអភិវឌ្ឍបៃតងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវផ្អែកលើអភិក្រម **“រក្សាតុល្យការរវាងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាប័ន្ន ជាមួយនឹងតម្រូវការបៃតង”** ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្នើ ADB បន្តគាំទ្រគម្រោងក្នុងវិស័យអាទិភាពមួយចំនួន÷ ១. ការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីអាចធានាសន្តិសុខស្បៀងផង និងជំរុញការធ្វើពាណិជ្ជូបនីយកម្មផង, ២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដោយផ្តោតជាពិសេសលើការរៀបចំប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្ម និងការគ្រប់គ្រងសំណល់ផ្សេងៗ ដោយមានការរៀបចំផែនការមេ និងផែនការវិនិយោគច្បាស់លាស់ រួមទាំងការគិតគូរអំពីយន្តការស្រង់ថ្លៃដើមថ្លៃវិនិយោគ (Cost recovery) និងនិរន្តរភាពប្រតិបត្តិការផងដែរ, និង ៣. ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព តាមរយៈការវិនិយោគសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រស្របតាមផែនការមេច្បាស់លាស់ ដើម្បីគាំពារជីវភាពរបស់ប្រជាកសិករ, ការលើកកម្ពស់កំណើនក្នុងវិស័យកសិកម្ម, ការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ ADB ដែលបានចូលរួម និងជំរុញការអភិវឌ្ឍគម្រោងវិនិយោគសាធារណៈតាម **“យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន”** នៅកម្ពុជា សម្រាប់ការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានពីវិស័យឯកជន និងគាំទ្រយ៉ាងពេញទំហឹងលើគោលដៅប្រកបដោយមហិច្ឆតារបស់ ADB ក្នុងការប្រែ-ក្លាយខ្លួនជាដៃគូអភិវឌ្ឍន៍ពហុភាគីធំបំផុតនៅកម្ពុជា ដោយនឹងផ្តល់ឥណទានដល់វិស័យឯកជន សម្រាប់ពង្រីកធុរកិច្ច និងប្រតិបត្តិការនៅកម្ពុជា ជាពិសេស គាំទ្រការពង្រីកលទ្ធភាពរបស់វិស័យឯកជនក្នុងការចូលរួមអនុវត្ត PPP ។